# សាលាក្រុង Fairfield

# ផែនការសកម្មភាពការរួមបញ្ចូលជនពិការឆ្នាំ 2022–2026

**Khmer | ភាសាខ្មែរ**

**កំណែងាយស្រួលអាន**

ងាយស្រួលអាន



FairfieldCity
Celebrating diversity

# របៀបប្រើប្រាស់ផែនការនេះ




សាលាក្រុង Fairfield (Fairfield City Council) បានសរសេរផែនការនេះ។ នៅពេលអ្នកឃើញពាក្យថា ‘យើង’ វាមានន័យថា សាលាក្រុង Fairfield។




យើងបានសរសេរព័ត៌មាននេះតាមរបៀបមួយដែលងាយស្រួលអាន។

យើងប្រើប្រាស់រូបភាពនានាដើម្បីពន្យល់គំនិតមួយចំនួន។

**អក្សរដិត**

អក្សរមិនដិត

យើងបានសរសេរពាក្យសំខាន់ៗមួយចំនួនជា **អក្សរដិត**។

នេះមានន័យថាអក្សរនានាគឺក្រាស់ជាង និងខ្មៅជាង។




យើងពន្យល់ពីអត្ថន័យនៃពាក្យដិតទាំងនេះមានន័យដូចម្ដេច។

មានបញ្ជីពាក្យទាំងនេះនៅលើទំព័រ 26។



ផែនការងាយស្រួលអាននេះគឺជាសេចក្ដីសង្ខេបនៃផែនការមួយទៀត។

នេះមានន័យថាវារួមបញ្ចូលតែគំនិតសំខាន់ៗបំផុតប៉ុណ្ណោះ។

អ្នកអាចរកផែនការមួយទៀតនៅលើគេហទំព័ររបស់យើង។




**www.fairfieldcity.nsw.gov.au/Community/Our-People/People-with-Disability**



អ្នកអាចស្នើសុំជំនួយដើម្បីអានផែនការនេះ។ មិត្តភក្ដិ សមាជិកគ្រួសារ ឬអ្នកជួយគាំទ្រ ប្រហែលជាអាច ជួយ អ្នកបាន។

# តើមានអ្វីខ្លះនៅក្នុងផែនការនេះ?


| | |
|---|---|
| អ្វីដែលយើងចង់បានសម្រាប់សាលាក្រុង Fairfield City | 4 |
| អំពីសាលាក្រុង Fairfield City | 7 |
| អ្វីខ្លះដែលយើងត្រូវការធ្វើ | 9 |
| តើយើងបានបង្កើតផែនការរបស់យើងដោយរបៀបណា? | 12 |
| ផែនការសកម្មភាពការរួមបញ្ចូលជនពិការរបស់យើង | 14 |
| 1. អាកប្បកិរិយា និងឥរិយាបថល្អ | 16 |
| 2. សហគមន៍ដែលល្អសម្រាប់រស់នៅ | 18 |
| 3. ការជួយមនុស្សដែលមានពិការភាពទទួលបានការងារល្អៗ | 20 |
| 4. សេវាកម្ម និងវិធីធ្វើកិច្ចការនានារបស់យើង | 22 |
| ការធ្វើឱ្យប្រាកដថាផែនការរបស់យើងដំណើរការបានល្អ | 24 |
| បញ្ជីពាក្យ | 26 |
| ទាក់ទងមកយើង | 27 |

## អ្វីដែលយើងចង់បានសម្រាប់សាលាក្រុង Fairfield City



យើងចង់ធ្វើឱ្យសាលាក្រុង Fairfield City **មានលក្ខណៈកាន់តែងាយស្រួលចូលប្រើប្រាស់**សម្រាប់ជនពិការ។



នៅពេលសហគមន៍មានលក្ខណៈងាយស្រួលចូលប្រើប្រាស់សម្រាប់ជនពិការ វាងាយស្រួលដើម្បី៖

- រក និងប្រើប្រាស់របស់របរនានា
- ធ្វើដំណើរជុំវិញ។



យើងក៏ចង់ឱ្យសាលាក្រុង Fairfield City កាន់តែមាន **លក្ខណៈរួមបញ្ចូល**ផងដែរ។



នៅពេលសហគមន៍មានលក្ខណៈងាយស្រួលចូលប្រើប្រាស់សម្រាប់ជនពិការ មនុស្សគ្រប់រូបអាច៖

- ចូលរួម
- មានអារម្មណ៍ដូចពួកគេធ្វើជាកម្មសិទ្ធិ។



ប្រសិនបើសាលាក្រុង Fairfield City មានលក្ខណៈងាយស្រួលចូលប្រើប្រាស់សម្រាប់ជនពិការ និងមានលក្ខណៈរួមបញ្ចូល ពេលនោះយើង អាចជួយមនុស្សឱ្យធ្វើកិច្ចការប្រចាំថ្ងៃបានកាន់តែច្រើនថែមទៀតសម្រាប់ខ្លួនពួកគេផ្ទាល់។

ការនេះក៏ជួយផងដែរដល់៖



- មនុស្សវ័យចាស់



- មនុស្សដែលប្រើរទេះរុញជនពិការ ឬរទេះរុញទារក។



វាក៏សំខាន់ផងដែរសម្រាប់អាជីវកម្ម និងសេវាកម្មនានា នៅតាមតំបន់ដែលត្រូវមានលក្ខណៈងាយស្រួលចូលប្រើប្រាស់សម្រាប់ជនពិការ និងមានលក្ខណៈរួមបញ្ចូល។



ការរក និងការរក្សាការងារក៏អាចជួយមនុស្សផងដែរឱ្យមានអារម្មណ៍ថាពួកគេធ្វើជាកម្មសិទ្ធិ។

យើងចង់ឱ្យសាលាក្រុង Fairfield City ក្លាយជាកន្លែងមួយដែលមនុស្សមានពិការភាពអាចចែករំលែកនូវ៖



- ជំនាញ



- ចំណេះដឹង



- បទពិសោធន៍របស់ពួកគេ។



សហគមន៍របស់យើងនឹងកាន់តែរឹងមាំ ប្រសិនបើយើងស្តាប់មនុស្សដែលមានពិការភាព។

## អំពីសាលាក្រុង Fairfield City




ក្នុងឆ្នាំ 2021, 9.3% នៃពលរដ្ឋនៅក្នុងសាលាក្រុង Fairfield City៖

- មានពិការភាព
- ត្រូវការការគាំទ្រជាមួយសកម្មភាពប្រចាំថ្ងៃ។




11.5% នៃពលរដ្ឋនៅក្នុងសាលាក្រុង Fairfield City ក៏បានផ្តល់ការថែទាំដែលមិនបង់ប្រាក់ឱ្យមនុស្សម្នាក់ទៀតផងដែរក្នុងឆ្នាំ 2021។

នេះរួមមានការថែទាំសម្រាប់៖



- មនុស្សដែលមានពិការភាព



- មនុស្សមានបញ្ហាសុខភាពដែលនឹងស្ថិតនៅអស់រយៈពេលយូរ



- មនុស្សវ័យចាស់។




ក្នុងឆ្នាំ 2016 ជាងពាក់កណ្ដាលនៃមនុស្សដែលមានពិការភាពមានអាយុ 65 ឆ្នាំ ឬអាយុលើសនេះ។



ហើយមនុស្ស 1 នាក់ ក្នុងចំណោមមនុស្ស 6 នាក់ដែលមានពិការភាពនៅសាលាក្រុង Fairfield City បាន៖

- សិក្សា
- បញ្ចប់វគ្គសិក្សាមួយ។




ក្នុងឆ្នាំ 2016 មានមនុស្ស 13,359 នាក់ ដែលរស់នៅក្នុងសាលាក្រុង Fairfield City៖

- បានកើតនៅបរទេស
- ត្រូវការការគាំទ្រសម្រាប់សកម្មភាពប្រចាំថ្ងៃ។

# អ្វីខ្លះដែលយើងត្រូវការធ្វើ




យើងមានច្បាប់នៅក្នុងរដ្ឋ New South Wales ហៅថា *ច្បាប់ការរួមបញ្ចូលជនពិការឆ្នាំ 2014* (ច្បាប់)។




ច្បាប់នេះពន្យល់ពីបទប្បញ្ញត្តិនានាដែលមនុស្សគ្រប់រូបត្រូវអនុវត្តតាម។



ច្បាប់នេះធ្វើឱ្យប្រាកដថាមនុស្សដែលមានពិការភាពនៅក្នុងរដ្ឋ New South Wales ត្រូវបានគេប្រព្រឹត្តិមកលើត្រឹមត្រូវ។




ច្បាប់នេះចែងថាយើងត្រូវតែមានផែនការសកម្មភាពការរួមបញ្ចូលជនពិការ។

យើងហៅវាថាផែនការ។



ក៏មានវិធីខុសៗគ្នាផងដែរដែលយើងធ្វើឱ្យសាលាក្រុង Fairfield City កាន់តែមានលក្ខណៈងាយស្រួលចូលប្រើប្រាស់សម្រាប់ជនពិការ និងមានលក្ខណៈរួមបញ្ចូល។



យើងត្រូវការគាំទ្រចំពោះ **អាកប្បកិរិយា** និងឥរិយាបទល្អៗនៅក្នុងសហគមន៍សាលាក្រុង Fairfield City។

អាកប្បកិរិយារបស់យើងគឺជាអ្វីដែលយើងគិត មានអារម្មណ៍ និងជឿជាក់។



យើងត្រូវការស្តាប់សហគមន៍។

ការធ្វើដូចនេះនឹងជួយឱ្យយើងយល់ដឹងពីអ្វីដែលមនុស្សរស់នៅក្នុងសាលាក្រុង Fairfield City ត្រូវការ។




យើងអាចប្រើប្រាស់ព័ត៌មាននេះដើម្បីធ្វើឱ្យប្រាកដថា សេចក្តីសម្រេច និងផែនការទាំងឡាយរបស់យើងនឹងដំណើរបានល្អសម្រាប់សហគមន៍របស់យើង។

នេះរួមទាំងការធ្វើឱ្យប្រាកដថា៖



- សេវាកម្មនានារបស់យើងមានលក្ខណៈរួមបញ្ចូល



- កន្លែងសាធារណៈរបស់យើងមានលក្ខណៈងាយស្រួលចូលប្រើប្រាស់សម្រាប់ជនពិការ។




យើងក៏ត្រូវការធ្វើការជាមួយអង្គការដទៃទៀតផងដែរ ដើម្បីសម្រេចបានគោលដៅនានារបស់យើង។

# តើយើងបានបង្កើតផែនការរបស់យើងដោយរបៀបណា?



យើងបានសួរសហគមន៍អំពីរបៀបដែលយើងមានអាច លក្ខណៈងាយស្រួលចូលប្រើប្រាស់សម្រាប់ជនពិការ និងមានលក្ខណៈរួមបញ្ចូលច្រើនទៀត។

យើងបានឮពីៈ



- មនុស្សដែលមានពិការភាព



- គ្រួសារ និងអ្នកថែទាំរបស់ពួកគេ។

យើងក៏បាននិយាយជាមួយៈ



- អង្គការជនពិការនានា




- បុគ្គលិកសាលាក្រុង Fairfield (Fairfield City Council)។




យើងបានរួមបញ្ចូលគំនិតរបស់មនុស្សគ្រប់រូបនៅក្នុង
ផែនការថ្មីរបស់យើង។



យើងសូមអរគុណដល់មនុស្សគ្រប់រូបដែលបានចែក
រំលែកគំនិតរបស់ពួកគេជាមួយយើង។

# ផែនការសកម្មភាពការរួមបញ្ចូលជនពិការរបស់យើង




ផែនការរបស់យើងពន្យល់ពីរបៀបដែលយើងនឹងធ្វើឱ្យសាលាក្រុង Fairfield City របស់យើង កាន់តែមានលក្ខណៈងាយស្រួលចូលប្រើប្រាស់សម្រាប់ជនពិការ និងមានលក្ខណៈរួមបញ្ចូល។

**ប្រធានបទ** គឺជាគំនិតសំខាន់ៗដែលចេញមកពីផ្នែកផ្សេងៗនៃការងារ និងជីវិតរបស់យើង។

ផែនការរបស់យើងមានប្រធានបទសំខាន់ៗចំនួន 4។



1. អាកប្បកិរិយា និងឥរិយាបថល្អ



2. សហគមន៍ដែលល្អសម្រាប់រស់នៅ



3. ការជួយមនុស្សដែលមានពិការភាពឱ្យទទួលបានការងារល្អៗ



4. សេវាកម្ម និងវិធីធ្វើកិច្ចការនានារបស់យើង

ប្រធានបទនីមួយៗនិយាយអំពីៈ




- គោលដៅនានារបស់យើងសម្រាប់ប្រធានបទនោះ




- អ្វីដែលយើងនឹងធ្វើ។

# 1. អាកប្បកិរិយា និងឥរិយាបថល្អ

## តើអ្វីជាគោលដៅរបស់យើង?



យើងចង់ឱ្យសហគមន៍មានអាកប្បកិរិយា និង ឥរិយាបថល្អចំពោះមនុស្សដែលមានពិការភាព។

ហើយស្វែងយល់ថាវាមានសារសំខាន់យ៉ាងណាដែលត្រូវមានលក្ខណៈរួមបញ្ចូល។



យើងក៏ចង់ឱ្យបុគ្គលិករបស់យើងយល់ដឹងអំពីពិការភាពកាន់តែប្រសើរឡើងផងដែរ។

## តើយើងនឹងធ្វើអ្វីខ្លះ?



យើងនឹងចែករំលែកព័ត៌មានជាមួយសហគមន៍ អំពីសេចក្តីត្រូវការរបស់មនុស្សដែលមានពិការភាព។

យើងក៏នឹងគាំទ្រដល់ព្រឹត្តិការណ៍នានាផងដែរដែលៈ



- មានលក្ខណៈងាយស្រួលចូលប្រើប្រាស់សម្រាប់ជនពិការ និងមានលក្ខណៈរួមបញ្ចូល



- អបអរសារទរចំពោះមនុស្សដែលមានពិការភាព។



យើងនឹងហ៊ាននិយាយអំពីការធ្វើឱ្យកន្លែង និងទីលំហនានាកាន់តែមានលក្ខណៈងាយស្រួលចូលប្រើប្រាស់សម្រាប់ជនពិការ និងមានលក្ខណៈរួមបញ្ចូល។



យើងនឹងបន្តរក្សាការបណ្តុះបណ្តាលបុគ្គលិករបស់យើងឱ្យយល់ដឹងអំពីសេចក្តីត្រូវការរបស់មនុស្សដែលមានពិការភាព។

## 2. សហគមន៍ដែលល្អសម្រាប់រស់នៅ

### តើអ្វីជាគោលដៅរបស់យើង?



យើងចង់ឱ្យសាលាក្រុង Fairfield City ជាកន្លែងដែលមានលក្ខណៈងាយស្រួលចូលប្រើប្រាស់សម្រាប់ជនពិការ។



ការនេះនឹងធ្វើឱ្យកាន់តែងាយស្រួលសម្រាប់មនុស្សធ្វើដំណើរជុំវិញ។



យើងចង់ឱ្យព្រឹត្តិការណ៍នានារបស់យើងនឹងមានលក្ខណៈងាយស្រួលចូលប្រើប្រាស់សម្រាប់ជនពិការ និងមានលក្ខណៈរួមបញ្ចូល។



ហើយយើងចង់ឱ្យសកម្មភាព និងសេវាកម្មសហគមន៍នានារបស់យើងនឹងមានលក្ខណៈងាយស្រួលចូលប្រើប្រាស់សម្រាប់ជនពិការ។



យើងក៏ចង់គាំទ្រដល់អាជីវកម្មនានាដើម្បីធ្វើឱ្យអគាររបស់ពួកគេកាន់តែមានលក្ខណៈងាយស្រួលចូលប្រើប្រាស់សម្រាប់ជនពិការផងដែរ។

## តើយើងនឹងធ្វើអ្វីខ្លះ?

យើងនឹងបន្តធ្វើឱ្យទីលំហសាធារណៈនានាមានលក្ខណៈ ងាយស្រួលចូលប្រើប្រាស់សម្រាប់ជនពិការ រួមមាន៖



- អគារនានា



- កន្លែងចតរថយន្ត និងទីធ្លាក្មេងលេង។



យើងនឹងធ្វើឱ្យប្រាកដថាមនុស្សដែលមានពិការភាព អាចរក និងប្រើប្រាស់សេវាកម្មនានាដែលមាននៅ ក្នុងសហគមន៍របស់យើង។



នេះរួមមានកម្មវិធីអន្តរាគមន៍សម្រាប់កុមារ Fairstart (Fairstart Early Intervention program)។

កម្មវិធីនេះគាំទ្រដល់កុមារវ័យក្មេងៗដែលមានពិការភាព ដើម្បីចូលរួមក្នុងសហគមន៍។



យើងនឹងធ្វើឱ្យប្រាកដថាសេវាកម្មដទៃទៀតមាន លក្ខណៈងាយស្រួលចូលប្រើប្រាស់សម្រាប់ជនពិការ។

ឧទាហរណ៍ អាងហែលទឹក។

# 3. ការជួយមនុស្សដែលមានពិការភាពទទួលបានការងារល្អៗ

## តើអ្វីជាគោលដៅរបស់យើង?



យើងចង់ឱ្យសាលាក្រុង Fairfield City Council ក្លាយជាកន្លែងមួយដែលមនុស្សមានពិការភាពចង់ធ្វើការ។



យើងអាចធ្វើដូច្នេះបានដោយការមានលក្ខណៈរួមបញ្ចូល នៅពេលយើងជួលមនុស្សឱ្យធ្វើការ។

យើងក៏ចង់ជួយមនុស្សដែលមានពិការភាពផងដែរ៖



- ឱ្យទទួលបានការបណ្តុះបណ្តាល



- រក និងរក្សាការងារ។

## តើយើងនឹងធ្វើអ្វីខ្លះ?



យើងនឹងធ្វើឱ្យប្រាកដថាយើងផ្តល់ឱ្យមនុស្សដែលមានពិការភាពនូវឱកាសនានាដើម្បីធ្វើការនៅសាលាសង្កាត់។



យើងនឹងធ្វើការជាមួយអាជីវកម្មក្នុងតំបន់នានាដើម្បីជួយពួកគេឱ្យយល់ដឹងអំពីហេតុផលល្អៗដើម្បីជួលមនុស្សដែលមានពិការភាពឱ្យធ្វើការ។



យើងក៏នឹងគាំទ្រដល់មនុស្សដែលមានពិការភាពផងដែរ ដើម្បីធ្វើឱ្យជំនាញការងាររបស់ពួកគេរីកចម្រើន ដូចជា **អ្នកធ្វើការស្ម័គ្រចិត្ត**។

អ្នកធ្វើការស្ម័គ្រចិត្តគឺជាមនុស្សដែលធ្វើការប៉ុន្តែមិនទទួលបានបៀវត្សរ៍។

ជាធម្មតា អ្នកធ្វើការស្ម័គ្រចិត្តធ្វើការងារដែលជួយដល់មនុស្សដទៃទៀត។

## 4. សេវាកម្ម និងវិធីធ្វើកិច្ចការនានារបស់យើង

### តើអ្វីជាគោលដៅរបស់យើង?



យើងចង់ឱ្យវាកាន់តែងាយស្រួលថែមទៀតសម្រាប់មនុស្សដែលមានពិការភាព ដើម្បីរក និងប្រើប្រាស់សេវាកម្មនានារបស់យើង។



យើងក៏ចង់ធ្វើការឱ្យបានល្អជាមួយបណ្តាអង្គការដទៃទៀតដើម្បីផ្តល់សេវាកម្មនានាដែលមានលក្ខណៈងាយស្រួលចូលប្រើប្រាស់សម្រាប់ជនពិការ និងមានលក្ខណៈរួមបញ្ចូល។

## តើយើងនឹងធ្វើអ្វីខ្លះ?



យើងនឹងធ្វើឱ្យប្រាកដថាព័ត៌មានរបស់យើងមានលក្ខណៈងាយស្រួលចូលប្រើប្រាស់សម្រាប់ជនពិការ។

នេះរួមទាំងព័ត៌មាននៅលើគេហទំព័ររបស់យើង។



យើងនឹងធ្វើឱ្យប្រាកដថាមនុស្សដែលមានពិការភាពអាចចែករំលែកអ្វីដែលពួកគេគិតអំពីការងាររបស់យើង។




យើងនឹងធ្វើឱ្យប្រាកដថាការបោះឆ្នោតនៅតាមសាលាសង្កាត់របស់យើងមានលក្ខណៈរួមបញ្ចូល និងមានលក្ខណៈងាយស្រួលចូលប្រើប្រាស់សម្រាប់ជនពិការ។

# ការធ្វើឱ្យប្រាកដថាផែនការរបស់យើងដំណើរការបានល្អ




ផែនការរបស់យើងនឹងមានរយៈពេល 4 ឆ្នាំ។

យើងនឹងពិនិត្យមើលផែនការរបស់យើងជារៀងរាល់ឆ្នាំ ដើម្បីស្វែងយល់ថា៖



- អ្វីដែលដំណើរការបានល្អ



- អ្វីដែលត្រូវការផ្លាស់ប្តូរ។




យើងក៏នឹងសរសេររបាយការណ៍មួយជារៀងរាល់ឆ្នាំផងដែរ។




យើងនឹងចែករំលែករបាយការណ៍នេះជាមួយសហគមន៍។

# បញ្ជីពាក្យ

បញ្ជីនេះពន្យល់ពីពាក្យ **ដែលសរសេរដិត** នៅក្នុងឯកសារ
នេះមានន័យដូចម្តេច។



## មានលក្ខណៈងាយស្រួលចូលប្រើប្រាស់សម្រាប់ជនពិការ

នៅពេលសហគមន៍មានលក្ខណៈងាយស្រួលចូលប្រើ
ប្រាស់សម្រាប់ជនពិការ វាងាយស្រួលដើម្បី៖

- រក និងប្រើប្រាស់របស់របរនានា
- ធ្វើដំណើរជុំវិញ។



## អាកប្បកិរិយា

អាកប្បកិរិយារបស់យើងគឺជាអ្វីដែលយើងគិត
មានអារម្មណ៍ និងជឿជាក់។



## មានលក្ខណៈរួមបញ្ចូល

នៅពេលសហគមន៍មានលក្ខណៈងាយស្រួលចូលប្រើ
ប្រាស់សម្រាប់ជនពិការ មនុស្សគ្រប់រូបអាច៖

- ចូលរួម
- មានអារម្មណ៍ដូចពួកគេធ្វើជាកម្មសិទ្ធិ។



## ប្រធានបទនានា

ប្រធានបទទាំងនេះគឺជាគំនិតសំខាន់ៗដែលចេញមក
ពីផ្នែកផ្សេងៗនៃការងារ និងជីវិតរបស់យើង។



## អ្នកធ្វើការស្ម័គ្រចិត្ត

អ្នកធ្វើការស្ម័គ្រចិត្តគឺជាមនុស្សដែលធ្វើការ
ប៉ុន្តែមិនទទួលបានបៀវត្សរ៍។
ជាធម្មតា អ្នកធ្វើការស្ម័គ្រចិត្តធ្វើការងារ
ដែលជួយដល់មនុស្សដទៃទៀត។

# ទាក់ទងមកយើង

អ្នកអាចហៅទូរសព្ទមកយើង។

**(02) 9725 0222**

អ្នកអាចផ្ញើអ៊ីមែលមកយើង។

**mail@fairfieldcity.nsw.gov.au**

អ្នកអាចសរសេរមកយើង។

PO Box 21

Fairfield NSW 1860

អ្នកអាចចូលមើលគេហទំព័ររបស់យើង។

**www.fairfieldcity.nsw.gov.au**

ក្រុមចូលប្រើប្រាស់ព័ត៌មាន (Information Access Group) បានបង្កើតឯកសារងាយស្រួលអាននេះ ដោយប្រើរូបថតផ្តល់ឱ្យមានអាជ្ញាប័ណ្ណ និងរូបភាពមានលក្ខណៈផ្ទាល់ខ្លួន។ មិនត្រូវប្រើប្រាស់រូបភាពនានាអាចដោយគ្មានការអនុញ្ញាតឡើយ។ សម្រាប់ការសាកសួរណាមួយអំពីរូបភាព សូមចូលមើល **www.informationaccessgroup.com**។ សម្រង់លេខការងារ 5015។